Australian Government

jobactive

# jobactive - ជួយលោកអ្នករកបានការងារធ្វើ

jobactive គឺជាមធ្យោបាយមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីជួយពលរដ្ឋអូស្ត្រាលីចំនួនកាន់តែច្រើន ចូលទៅក្នុងការងារ។ វាជួយតភ្ជាប់អ្នកស្វែងរកការងារជាមួយនឹងនិយោជក ហើយផ្តល់ជូនដោយបណ្តាញនៃស្ថាប័ន jobactive ជាង១៧០០កន្លែង នៅទូទាំងប្រទេសអូស្ត្រាលី។

ក្នុងនាមអ្នកស្វែងរកការងារធ្វើ ស្ថាប័ន jobactive របស់លោកអ្នក អាចជួយលោកអ្នក៖

- សរសេរប្រវត្តិរូបសង្ខេប
- ស្វែងរកការងារ
- រៀបចំខ្លួនដើម្បីសម្ភាសន៍
- ទទួលបានជំនាញដែលនិយោជកត្រូវការ
- ស្វែងរកការងារ និងរក្សាទុកការងារ។

## តើខ្ញុំមានសិទ្ធិទទួលបាន jobactive ឬទេ?

សេវាកម្មនានារបស់ jobactive ជាទូទៅតែងមានផ្តល់ជូនលោកអ្នក ប្រសិនបើលោកអ្នកទទួលប្រាក់ផ្គត់ផ្គង់លើប្រាក់ចំណូល ដូចជា Newstart Allowance, Youth Allowance (ឯទៀត) ឬ Parenting Payment ហើយមានតម្រូវការកាតព្វកិច្ចទៅវិញទៅមក។ កាតព្វកិច្ចទៅវិញទៅមក គឺជាកិច្ចការជាក់លាក់មួយចំនួន ដែលលោកអ្នកចាំបាច់ត្រូវបំពេញ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភរបស់លោកអ្នក ដូចជាការស្វែងរកការងារធ្វើជាដើម។

Department of Human Services របស់រដ្ឋាភិបាលអូស្ត្រាលី នឹងវាយតម្លៃទៅលើកាលៈទេសៈ និងសិទ្ធិទទួលបានរបស់លោកអ្នក សម្រាប់ jobactive រួចបញ្ជូនលោកអ្នកទៅកាន់ស្ថាប័ន jobactive។

ប្រសិនបើលោកអ្នកមិនបានទទួលប្រាក់ផ្គត់ផ្គង់លើប្រាក់ចំណូលទេ ឬលោកអ្នកកំពុងទទួលប្រាក់ផ្គត់ផ្គង់លើប្រាក់ចំណូល ហើយមិនមានកាតព្វកិច្ចទៅវិញទៅមកទេ លោកអ្នកអាចស្ម័គ្រចិត្តធ្វើការសម្រាប់សេវាកម្មនានារបស់ jobactive ប្រសិនបើលោកអ្នក៖

- មិនធ្វើការងារ ឬកំពុងសិក្សាពេញម៉ោង ហើយ
- មានសិទ្ធិធ្វើការងារនៅក្នុងប្រទេសអូស្ត្រាលី ។

## តើខ្ញុំអាចទទួលបានជំនួយអ្វីខ្លះ?

ស្ថាប័ន jobactive មានភាពបត់បែនក្នុងការកែសម្រួលសេវាកម្មនានារបស់ពួកគេ ទៅតាមសេចក្តីត្រូវការដែលបានធ្វើការវាយតម្លៃរបស់លោកអ្នក ដើម្បីជួយលោកអ្នករកបានការងារ ហើយរក្សាទុកការងារនោះ។

ស្ថាប័ន jobactive របស់លោកអ្នក នឹងជួបជាមួយលោកអ្នក ដើម្បីជួយលោកអ្នកស្វែងរកការងារ ហើយបង្កើត Job Plan មួយដែលអាចដាក់បញ្ចូល៖

- សកម្មភាពនានា ដើម្បីជួយលោកអ្នកទទួលបានជំនាញដែលនិយោជកក្នុងតំបន់កំពុងស្វែងរក
- ជំនួយសម្រាប់លោកអ្នកដើម្បីជំនះ ឬគ្រប់គ្រងបញ្ហាមិនមែនជំនាញវិជ្ជាជីវៈ ពេលណាដែលទាក់ទិន
- ការស្វែងរកការងាររហូតទៅដល់២០ការងារ ជារៀងរាល់ខែ - ស្ថាប័ន jobactive របស់លោកអ្នក អាចកែសម្រួលតួលេខនេះ ទៅតាមកាលៈទេសៈរបស់លោកអ្នក និងស្ថានភាពទីផ្សារការងារក្នុងតំបន់
- Work for the Dole (ធ្វើការសម្រាប់ប្រាក់ឥតការងារធ្វើ) ឬសកម្មភាពដែលបានយល់ព្រមឯទៀត (ដូចជាការងារមិនពេញពេល ការសិក្សាមិនពេញពេលនៅក្នុងវគ្គសិក្សាដែលមានសិទ្ធិទទួលបាន ការចូលរួមនៅក្នុងភាសាដែលរដ្ឋទទួលស្គាល់ និងការហ្វឹកហ្វឺនផ្នែកអក្ខរកម្ម និងការគិតលេខ ឬការងារស្ម័គ្រចិត្ត) សម្រាប់រយៈពេលប្រាំមួយខែ ជារៀងរាល់ឆ្នាំ។

ដើម្បីជួយលោកអ្នកទទួលបានការងារ និងរក្សាទុកការងារនោះ ស្ថាប័ន jobactive របស់លោកអ្នកអាចមានលទ្ធភាពទទួលបានផ្តល់ថវិកាដើម្បីបង់ថ្លៃចំណាយពាក់ព័ន្ធនឹងការងារ ថ្លៃសេវាវិជ្ជាជីវៈ ការបណ្តុះបណ្តាលដែលពាក់ព័ន្ធ និងការគាំទ្របន្ទាប់ពីលោកអ្នកចាប់ផ្តើមធ្វើការងារ។

## តើខ្ញុំគួរធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំមានកង្វល់អំពីបរិស្ថានទីកន្លែងធ្វើការងាររបស់ខ្ញុំ?

អង្គការទទួលចាត់ចែង Work for the Dole របស់លោកអ្នក គួរប្រាប់លោកអ្នកពីរបៀបរាយការណ៍អំពីបញ្ហាសុខភាព និងសុវត្ថិភាពការងារ ហើយនិងកង្វល់ផ្សេងៗទៀត។ ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងរបៀបដែលអង្គការទទួលចាត់ចែងរបស់លោកអ្នក ដោះស្រាយកង្វល់របស់លោកអ្នកទេ សូមទាក់ទងមកស្ថាប័ន jobactive របស់លោកអ្នក។

## តើលោកអ្នកចង់បានព័ត៌មានបន្ថែមឬទេ?

សូមចូលទៅកាន់
**www.employment.gov.au/jobactive**

ទូរស័ព្ទទៅ ខ្សែរទូរស័ព្ទផ្តល់ព័ត៌មានអំពីសេវាកម្មការងារ លេខ **13 62 68*** ឬនិយាយទៅកាន់ស្ថាប័នរបស់លោកអ្នក ប្រសិនបើលោកអ្នកបានចុះបញ្ជីរួចហើយជាមួយ jobactive ឬ Disability Employment Services (សេវារកការងារធ្វើសម្រាប់ជនពិការ)

ស្វែងរកស្ថាប័ន jobactive ក្នុងតំបន់នៅតាមវិបសាយ
**www.jobactive.gov.au**

ស្ថាប័នរបស់លោកអ្នក ក៏អាចនឹងភ្ជាប់លោកអ្នកទៅកាន់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលផ្សេងៗទៀតជាច្រើនផងដែរ។ គំនិតផ្តួចផ្តើមទាំងនេះ មានដូចជាជំនួយផ្លាស់ប្តូរទីលំនៅ ការឧបត្ថម្ភប្រាក់បៀវត្សរ៍ ការបណ្តុះបណ្តាល ការបង្រៀនជំនាញកូនជាង និងការជួយដើម្បីចាប់ផ្តើមអាជីវកម្ម តាមរយៈ New Enterprise Incentive Scheme (NEIS) (គម្រោងលើកទឹកចិត្តសហគ្រាសថ្មី)

## តើឧបករណ៍អ្វីខ្លះដែលមានសម្រាប់ខ្ញុំ?

ដើម្បីជួយលោកអ្នកស្វែងរកការងារធ្វើ ស្ថាប័ន jobactive របស់លោកអ្នក នឹងផ្តល់ជូនលោកអ្នកនូវលទ្ធភាពប្រើប្រាស់ខុមព្យូធើរ អ៊ិនធើណិត និងម៉ាស៊ីនបោះពុម្ពនៅក្នុងការិយាល័យរបស់ពួកគេ។ លោកអ្នកអាចប្រើប្រាស់ឧបករណ៍ទាំងនេះ ដើម្បីស្វែងរកការងារ និងដាក់ពាក្យសុំការងារនោះ រួចហើយរៀបចំប្រវត្តិរូបសង្ខេបរបស់លោកអ្នកឲ្យបានទាន់បច្ចុប្បន្នភាព និងបោះពុម្ពវា។

លោកអ្នកក៏អាចស្វែងរកការងារ និងចូលទៅកាន់សេវាតាមអ៊ិនធើណិតរបស់ jobactive ផងដែរ នៅត្រង់វិបសាយ **www.jobactive.gov.au** ឬកម្មវិធី Job Seeker Job Search app ឥតគិតថ្លៃ (ដែលអាចទទួលយកបានពី iTunes និង Google Play។)

ដោយការភ្ជាប់គណនី myGov របស់លោកអ្នកទៅកាន់គណនី JobSearch របស់លោកអ្នក លោកអ្នកអាចតាមដានការដាក់ពាក្យសុំការងាររបស់លោកអ្នក គ្រប់គ្រងការណាត់ជួបជាមួយស្ថាប័ននានា ទទួលបានការជូនដំណឹង និងគ្រប់គ្រងប្រវត្តិរូបសង្ខេបរបស់លោកអ្នក គឺអ្វីៗទាំងអស់ចេញពី dashboard (បន្ទះផ្ទុកព័ត៌មាន) ផ្ទាល់ខ្លួនរបស់លោកអ្នក។

កម្មវិធី Career Quiz App ក៏អាចជួយលោកអ្នកក្នុងការស្វែងយល់អំពីប្រភេទការងារដែលអាចសមស្របចំពោះលោកអ្នក ព្រមទាំងព័ត៌មានដែលមានប្រយោជន៍ដូចជា តើមានមនុស្សចំនួនប៉ុន្មាននាក់ត្រូវបានជួលនៅក្នុងឧស្សាហកម្មជាក់លាក់នានា ហើយថាតើពួកគេទទួលបានប្រាក់បៀវត្សរ៍ចំនួនប៉ុន្មាន។ លោកអ្នកក៏អាចទាញយក Career Quiz ពីហាង app store ផងដែរ ឬចូលទៅកាន់វិបសាយ **www.joboutlook.gov.au/careerquiz**

## តើគេរំពឹងទុកអ្វីខ្លះអំពីខ្ញុំ?

ប្រសិនបើលោកអ្នកទទួលបានប្រាក់ផ្គត់ផ្គង់លើប្រាក់ចំណូលរបស់លោកអ្នក ហើយមានតម្រូវការកាតព្វកិច្ចទៅវិញទៅមក លោកអ្នកចាំបាច់ត្រូវបញ្ចូលទៅក្នុង Job Plan មួយ ហើយបំពេញគ្រប់សកម្មភាពទាំងអស់ដែលបានរៀបរាប់ ដូចជាការបំពេញ៖

- ចំនួននៃការស្វែងរកការងារធ្វើដែលបានតម្រូវក្នុងមួយខែ និង
- Work for the Dole ឬសកម្មភាពដែលបានយល់ព្រមឯទៀត នៅក្នុងរយៈពេលប្រាំមួយខែ ជារៀងរាល់ឆ្នាំ។

លោកអ្នកចាំបាច់ក៏ត្រូវបំពេញតាមការបញ្ជូនរបស់ស្ថាប័នលោកអ្នកផងដែរ ទៅកាន់ការងារជាក់លាក់ទាំងឡាយនៅក្នុងតំបន់របស់លោកអ្នក។

ស្ថាប័ន jobactive របស់លោកអ្នក នឹងពន្យល់ ហើយធ្វើការជាមួយលោកអ្នក ដើម្បីជួយលោកអ្នកបំពេញទៅតាមតម្រូវការកាតព្វកិច្ចទៅវិញទៅមករបស់លោកអ្នក ។

## ការរំពឹងទុកសម្រាប់ការផ្តល់សេវាកម្ម

រដ្ឋាភិបាលអូស្ត្រាលី រំពឹងទុកថាស្ថាប័ន jobactive នឹងផ្តល់សេវាប្រកបដោយគុណភាពទៅដល់អ្នកស្វែងរកការងារធ្វើ និងដល់និយោជកទាំងឡាយ។

Service Guarantees (ការធានាចំពោះការផ្គត់ផ្គង់សេវា) ដែលថែងអំពីតម្រូវការផ្គត់ផ្គង់សេវារបស់ស្ថាប័ន អាចរកឃើញនៅតាមវិបសាយ **www.employment.gov.au**

ស្ថាប័ន jobactive ត្រូវបានតម្រូវឲ្យដាក់បង្ហាញពី Service Guarantees និងផែនការផ្គត់ផ្គង់សេវារបស់ពួកគេនៅក្នុងការិយាល័យរបស់ពួកគេ ហើយត្រូវប្រគល់ជូនឯកសារទាំងនោះដល់អ្នកស្វែងរកងារ និងនិយោជកទាំងឡាយ។ ផែនការរបស់ពួកគេក៏មានដាក់ផ្សព្វផ្សាយផងដែរនៅតាមវិបសាយ **www.jobsearch.gov.au**។

## តើលោកអ្នកត្រូវការជំនួយ អំពីសន្លឹកព័ត៌មាននេះឬទេ?

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយ (TIS) លេខ **131 450*** រួចស្នើសុំទូរស័ព្ទលេខ **13 62 68***

ប្រសិនបើលោកអ្នកអន់ខ្សោយលើការស្តាប់ ឬការនិយាយ លោកអ្នកអាចប្រើប្រាស់ National Relay Service បាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់
**www.relayservice.com.au**

*សូមកត់ចំណាំថា តម្លៃហៅទូរស័ព្ទនឹងត្រូវគិតថ្លៃ ចំពោះការហៅទូរស័ព្ទទៅលេខ ‘13’ ចេញពីទូរស័ព្ទចល័ត។

EM15-0117